# អត្ថបទវិភាគខ្លី៖ ការបែងចែកអាសនៈរដ្ឋសភាសម្រាប់ការបោះឆ្នោតឆ្នាំ២០១៨

ខែមករា ឆ្នាំ២០១៧

**សេចក្ដីផ្ដើម៖** អត្ថបទវិភាគខ្លីនេះនឹងផ្ដល់សាវតាសង្ខេបនៃក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ និងរូបមន្តគណនាចំនួនអាសនៈនៅក្នុងរដ្ឋសភាជាតិ ព្រមទាំងការបែងចែកអាសនៈតាមខេត្ត/ក្រុងនីមួយៗដូចមានចែងក្នុងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ(ច.ប.ជ.ត) នៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងបរិបទនៃការបោះឆ្នោតជាតិដែលនឹងប្រព្រឹត្តទៅនៅខែកក្កដា ឆ្នាំ២០១៨ខាងមុខនេះ អត្ថបទវិភាគអះអាងថា ចំនួនអាសនៈក្នុងរដ្ឋសភា និងការបែងចែកអាសនៈនៅក្នុង ច.ប.ជ.ត ចុងក្រោយនៅមានភាពខ្វះចន្លោះ ហើយអត្ថបទវិភាគផ្ដល់តួលេខចំនួនអាសនៈមួយផ្សេងទៀតដែលបានគណនាដោយផ្អែកលើការព្យាករណ៍ចំនួនប្រជាជន។

## សាវតា៖

ចំនួនអាសនៈនៅក្នុងរដ្ឋសភាមានការផ្លាស់ប្ដូរតិចតួចចាប់តាំងពីឆ្នាំ១៩៩៣មក ទោះបីជាចំនួនប្រជាពលរដ្ឋបន្តកើនឡើងក្នុងពេលពីរទសវត្សរ៍កន្លងមកនេះក៏ដោយ។ ដោយហេតុថាមិនមានតួលេខនៃចំនួនប្រជាពលរដ្ឋត្រូវបានផ្ដល់ជូនក្នុងពេលគណនា គួរបញ្ជាក់ផងដែរថាចំនួនអាសនៈសម្រាប់ការបោះឆ្នោតឆ្នាំ១៩៩៣ ត្រូវបានកំណត់ដោយចំនួនប្រជាពលរដ្ឋចុះឈ្មោះបោះឆ្នោត (មាត្រា៣០ នៃច្បាប់ស្ដីពីការបោះឆ្នោតរបស់អង្គការសហប្រជាជាតិសម្រាប់កម្ពុជា) ច.ប.ជ.ត ដែលបានអនុម័តនៅឆ្នាំ១៩៩៧ ចែងក្នុងមាត្រា៧ ថារៀងរាល់ឆ្នាំទីបីនៃនីតិកាលរបស់រដ្ឋសភា គណៈកម្មការកំណត់អាសនៈរដ្ឋសភាត្រូវបានបង្កើតឡើងដើម្បីកែប្រែ និងបែងចែកអាសនៈតាមខេត្ត ក្រុង។ ច.ប.ជ.ត ក៏ចែងពីរូបមន្តក្នុងការគណនាចំនួនអាសនៈសរុបក្នុងរដ្ឋសភា និងរូបមន្តគណនាអាសនៈតាមខេត្ត/ក្រុងនីមួយៗផងដែរ។

បើទោះជាយ៉ាងណាក៏ដោយ ច.ជ.ប.ត ដែលបានអនុម័តកាលពីឆ្នាំ២០១៥ បានកំណត់អាសនៈរដ្ឋសភាចំនួន ១២៥ សម្រាប់នីតិកាលរបស់រដ្ឋសភាឆ្នាំ២០១៨។ ច.ជ.ប.ត ថ្មីមិនបានដាក់បញ្ចូលមាត្រា៧ និងមាត្រា៨ ដែលបង្គាប់ឲ្យមានការបង្កើតគណៈកម្មការកំណត់ចំនួនអាសនៈរដ្ឋសភា និងមាត្រា៩ និងមាត្រា១០ ដែលចែងពីរូប

សម្រាប់សំនួរទាក់ទងនឹងអត្ថបទវិភាគខ្លីនេះ ឬសំនួរទូទៅអំពីវេទិកាអនាគតសូមទាក់ទងតាមរយៈអ៊ីម៉ែល៖
infor@futureforum.asia

មន្តសម្រាប់បែងចែកអាសនៈ។ វិសោធនកម្មនៃ ច.ជ.ប.ត មិនបានបង្ហាញពីហេតុផលនៃចំនួនអាសនៈ និងការបែងចែកទៅតាមខេត្តនោះទេ។

**ចំនួនអាសនៈសរុបៈ**

តារាងខាងក្រោមនេះបង្ហាញពីចំនួនអាសនៈរដ្ឋសភាសរុបដែលបានអនុម័តដោយនីតិកាលរបស់រដ្ឋសភាចាប់តាំងពីឆ្នាំ១៩៩៣ និងចំនួនអាសនៈដែលគណនាដោយឯករាជ្យដោយវេទិកាអនាគតតាមរូបមន្តសម្រាប់នីតិកាលនីមួយៗចាប់តាំងពីឆ្នាំ២០០៣។ លទ្ធផលពីការគណនាបង្ហាញថា ចំនួនអាសនៈរដ្ឋសភាគួរតែកើនឡើងបន្ថែមទៀត ប្រសិនមានការកែប្រែតាមរូបមន្តដែលបានចែងក្នុង ច.ជ.ប.ត ដោយផ្អែកលើកំណើនប្រជាពលរដ្ឋក្នុងនីតិកាលនីមួយៗរបស់រដ្ឋសភា។ គួរកត់សំគាល់ថា ប្រសិនបើមានការគណនាឡើងវិញរៀងរាល់អាណត្តិ ចំនួនអាសនៈសរុបក្នុងនីតិកាលឆ្នាំ២០១៨ មានការកើនឡើងច្រើនជាងចំនួនអាសនៈសរុប ដែលជាលទ្ធផលនៃការគណនាដោយផ្អែកលើតែអាសនៈដែលបានបែងចែកក្នុងនីតិកាលឆ្នាំ២០១៣ (យើងធ្វើការគណនានៅផ្នែកបន្ទាប់)។

| ឆ្នាំ | ចំនួនប្រជាជន(លាននាក់)[i] | ផលចែកប្រភាគ (ផ) | ចំនួនអាសនៈដែលបានអនុម័ត | ចំនួនអាសនៈដែលគណនាដោយរូបមន្ត |
|---|---|---|---|---|
| ១៩៩៣-១៩៩៤ | ៩,៨៧ | មិនមាន | ១២០ | មិនមាន |
| ១៩៩៨ | ១១,៤៤ | មិនមាន | ១២២ | មិនមាន |
| ២០០៣ | ១២,១៩ | ៩៥៤២២ | ១២៣ | ១២៧ |
| ២០០៨ | ១៣,៣២ | ១០១៥៨៤ | ១២៣ | ១៣១ |
| ២០១៣ | ១៤,៣៦ | ១០៦៣៦៤ | ១២៣ | ១៣៥ |
| ២០១៨ | ១៥,៥៧ | ១១១៦៩៣ | ១២៥ | ១៣៩ |

**ចំនួនអាសនៈតាមខេត្តៈ**

ក្រាបខាងក្រោមបង្ហាញពីចំនួនអាសនៈរដ្ឋសភាបែងចែកតាមខេត្តនីមួយៗសម្រាប់នីតិកាលឆ្នាំ២០១៨ ដែលបានកំណត់ក្នុង ច.ប.ជ.ត ធៀបនឹងចំនួនអាសនៈរដ្ឋសភាដែលគួរបែងចែកតាមខេត្តសម្រាប់នីតិកាលរបស់រដ្ឋសភាឆ្នាំ២០១៨ ប្រសិនបើប្រើរូបមន្តដែលបានកំណត់ក្នុងមាត្រា៩ និងមាត្រា១០ នៃ ច.ប.ជ.ត មុន។ ការគណនានៅក្នុងផ្នែកនេះ គឺជាការគណនាឆ្នាំដាច់ដោយឡែកដោយប្រើអាសនៈក្នុងរដ្ឋសភាបច្ចុប្បន្ន (១២៣) ហើយផលចែកប្រភាគ (ផ) មិនត្រូវបានគណនាក្នុងនីតិកាលមុនៗទេ។[ii] ការគណនាទាំងស្រុងមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ១។




ដោយផ្អែកលើកំណើនប្រជាជន ខេត្តមួយចំនួនគួរតែទទួលបានចំនួនអាសនៈបន្ថែមក្នុងមណ្ឌលរបស់ខ្លួនសម្រាប់ការបោះឆ្នោតឆ្នាំ២០១៨។ ទាំងរាជធានីភ្នំពេញ និងខេត្តសៀមរាបមិនមានការកើនឡើងចំនួនអាសនៈតាំងពីឆ្នាំ១៩៩៨ ដោយភ្នំពេញមានចំនួន ១២អាសនៈថេរ និង៦អាសនៈក្នុងខេត្តសៀមរាប។ ទោះបីជាភ្នំពេញមានចំនួនប្រជាជនកើនឡើងពី ៩៩៩.៨០៤នាក់ ក្នុងឆ្នាំ១៩៩៨ ទៅ ១.៨៣៥.០៩០នាក់ក្នុងឆ្នាំ២០១៥[iii] និងចំនួនប្រជាជន ក្នុងខេត្តសៀមរាបកើនពី ៦៩៦.១៦៤នាក់ ក្នុងឆ្នាំ១៩៩៨ ទៅ១.០៩៦.៤៨២នាក់ក្នុងឆ្នាំ២០១៥។ ចំនួនប្រជាជនមានការកើនឡើង មណ្ឌលទាំងពីរគួរទទួលបានអាសនៈចំនួន ៣ បន្ថែមទៀត ដោយភ្នំពេញគួរទទួលបាន ១៥អាសនៈ និងសៀមរាប ៩អាសនៈ។[iv] ដូចគ្នាដែរ ខេត្តបាត់ដំបងមានចំនួនប្រជាជនកើនឡើង ខេត្តនេះគួរទទួលបាន ២អាសនៈបន្ថែមទៀតដើម្បីបានអាសនៈសរុប១០ ប៉ុន្តែអាសនៈខេត្តបាត់ដំបងចប្ចុប្បន្ននៅត្រឹម៨ថេរតាំងពីឆ្នាំ១៩៩៨។ ខេត្តឧត្តរមានជ័យ[v] គួរទទួលបាន ១អាសនៈបន្ថែមទៀត។

ទន្ទឹមនឹងនេះការគណនាដោយប្រើរូបមន្តដែលចែងនៅក្នុង ច.ប.ជ.ត មុនការធ្វើវិសោធនកម្មឆ្នាំ២០១៥ បានបង្ហាញថាខេត្តខ្លះគួរមានចំនួនអាសនៈថយចុះ។ ខេត្តកំពង់ចាម[vi] មានការថយចុះអាសនៈច្រើនជាងគេ ដែលខេត្តនេះត្រូវថយចំនួន ៤អាសនៈពីអាសនៈសរុប១៨ និងខេត្តព្រៃវែងត្រូវថយចុះ ៣អាសនៈ។ ខេត្ត ៥ផ្សេងទៀតរួមមាន ខេត្តកំពង់ធំ កំពត ពោធិ៍សាត់ ស្វាយរៀង និងតាកែវគួរមានអាសនៈថយចុះ ទោះបីជាចំនួនប្រជជនក្នុងខេត្តទាំងនេះមានការកើនឡើងក៏ដោយ។[vii]

គួរបញ្ជាក់ថាខេត្តព្រះសីហនុត្រូវបានបែងចែក ២អាសនៈបន្ថែមទៀតនៅក្នុង ច.ប.ជ.ត វិសោធនកម្មឆ្នាំ ២០១៥ សម្រាប់នីតិកាលឆ្នាំ២០១៨ ដែលខេត្តនេះកើនឡើងអាសនៈសរុបរបស់ខ្លួនចំនួន៣អាសនៈ។ ជាថ្មីម្តងទៀត ដោយផ្អែកលើរូបមន្តដែលបានចែងក្នុង ច.ប.ជ.ត មុន ការគណនារបស់វេទិកាអនាគតបង្ហាញថាចំនួនប្រជាពលរដ្ឋក្នុងខេត្តនេះកើនឡើងតែ ១អាសនៈប៉ុណ្ណោះ។

> ច.ប.ជ.ត មុនធ្វើវិសោធនកម្មឆ្នាំ២០១៥ បានចែងក្នុងមាត្រា១០ថា "... *ចំពោះអាសនៈដែលនៅសល់ គណៈកម្មការកំណត់អាសនៈរដ្ឋសភា អាចធ្វើសំណើបន្ថែមអាសនៈទៅខេត្ត ក្រុងដោយផ្អែកតាមស្ថានភាពភូមិសាស្ត្រ សង្គម និងសេដ្ឋកិច្ច។*" ដោយចំនួនអាសនៈតាមខេត្តនីមួយៗត្រូវបានកំណត់ដោយរូបមន្តមិនគិតសំណល់ មានអាសនៈមួយចំនួននៅសល់ដោយមិនអាចជៀងវាងបានពីអាសនៈសរុប មិនអាចធ្វើការបែងចែកទៅខេត្តជាក់លាក់ណាមួយ។ ឧទាហរណ៍ លទ្ធផលនៃការគណនារបស់វេទិកាអនាគតសម្រាប់នីតិកាលឆ្នាំ ២០១៨បានកំណត់ចំនួនអាសនៈសរុប ១២៦ ប៉ុន្តែមានតែអាសនៈ១២១ ប៉ុណ្ណោះដែលត្រូវបានបែងចែកទូទាំង ២៥ ខេត្ត ក្រុង។ ដោយហេតុថាកត្តាដែលបានកំណត់នៅក្នុងមាត្រា ១០ មិនអាចកំណត់ជាចំនួនបាន ការបែងចែកអាសនៈនេះអាស្រ័យលើគណៈកម្មការសម្រេចថាខេត្តណាខ្លះគួរតែទទួលអាសនៈដែលនៅសល់។ ទោះបីជាវេទិកាអនាគតមិនអាចកំណត់ខេត្តណាខ្លះ ដែលគួរត្រូវបែងចែកអាសនៈ៥ ដែលនៅសល់នោះក៏ដោយ ការគណនានេះបង្ហាញច្បាស់ថា អាសនៈសរុបរបស់រដ្ឋសភាគួរកើនឡើងចំនួន ៣អាសនៈ មិនមែនកើនត្រឹម២អាសនៈដូចបានចែងនៅក្នុង ច.ប.ជ.ត នោះទេ។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖

ដោយមានកំណើនប្រជាជនទូទាំងប្រទេស និងបម្រែបម្រួលស្ថានភាពប្រជាសាស្ត្រគួរកត់សម្គាល់ជាពិសេសការធ្វើចំណាកស្រុកពីជនបទមកកាន់ទីក្រុង ការបែងចែកអាសនៈដែលត្រឹមត្រូវតាមមណ្ឌលផ្សេងៗគ្នា មានសារៈសំខាន់ក្នុងការធានាបានភាពតំណាងស្មើគ្នា។ ទោះជាយ៉ាងណាក្តីចំនួនអាសនៈសរុប និងការបែងចែកអាសនៈតាមខេត្ត/ក្រុងដែលចែងក្នុង ច.ប.ជ.ត ឆ្នាំ២០១៥ខុសពីលទ្ធផលដែលគណនាដោយវេទិកាអនាគត។ វេទិកាអនាគតស្នើនូវអនុសាសន៍ដូចខាងក្រោមដើម្បីធានាបាននូវការបែងចែកអាសនៈដែលត្រឹមត្រូវ និងយុត្តិធម៌៖

- ធ្វើវិសោធនកម្ម ច.ប.ជ.ត ដាក់បញ្ចូលវិញនូវមាត្រាដែលចែងអំពីរូបមន្តកំណត់ចំនួនអាសនៈ និងការបែងចែកអាសនៈតាមខេត្ត/ក្រុង
- វិសោធនកម្ម ច.ប.ជ.ត ដោយដាក់បញ្ចូលមកវិញនូវមាត្រាដែលចែងអំពីការបង្កើតគណៈកម្មការកំណត់ចំនួនអាសនៈរដ្ឋសភា រួមទាំង
- ធានាថាការបែងចែកអាសនៈនាពេលអនាគតត្រូវបានធ្វើឡើងប្រកបដោយតម្លាភាព ហើយការគណនា និងតួលេខដែលប្រើប្រាស់ក្នុងការកំណត់ចំនួនអាសនៈរដ្ឋសភានឹងត្រូវបង្ហាញជាសាធារណៈ។

**ឧបសម្ព័ន្ធ១៖ រូបមន្ត និងការគណនា**

រូបមន្តដែលចែងក្នុង ច.ប.ជ.ត (មុនការធ្វើវិសោធនកម្មឆ្នាំ២០១៥) មាត្រា៩៖

| |
|---|
| **$ប_{ផ}$/ $ច_{ប}$ = ផ ;  $ប_{ប}$/ផ = $ច_{ផ}$** |
| **$ប_{ផ}$** ជាចំនួនប្រជាពលរដ្ឋខ្មែរនៅពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចុងក្រោយកន្លងមក។ |
| **$ច_{ប}$** ជាចំនួនអាសនៈក្នុងរដ្ឋសភាបច្ចុប្បន្ន។ |
| ផ ជាផលចែកប្រភាគដោយពុំគិតចំនួនសល់។ |
| **$ប_{ប}$** ជាចំនួនប្រជាពលរដ្ឋខ្មែរបច្ចុប្បន្ន។ |
| **$ច_{ផ}$** ជាចំនួនអាសនៈថ្មី ដោយពុំគិតចំនួនសល់។ |

ដើម្បីគណនាផលចែកប្រភាគ (ផ) មានន័យថាចំនួនប្រជាជនដែលស្មើនឹងមួយអាសនៈ៖

**$ប_{ផ}$** ចំនួនប្រជាពលរដ្ឋខ្មែរនៅពេលបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចុងក្រោយកន្លងមក (ឆ្នាំ២០១៣) = ១៤.៩៦២.៥៩១នាក់

**$ច_{ប}$** ជាចំនួនអាសនៈក្នុងរដ្ឋសភាបច្ចុប្បន្ន= ១២៣ (ចំនួនអាសនៈនៅក្នុងឆ្នាំ២០១៥)

ផ = ១៤.៩៦២.៥៩១/ ១២៣= ១២១៦៤៧,០៨

**$ប_{ប}$** ជាចំនួនប្រជាពលរដ្ឋខ្មែរនៅឆ្នាំ២០១៥ (១៥.៤០៥.១៥៧)។ ដោយហេតុថាច្បាប់ស្តីពីការជ្រើសតាំងតំណាងរាស្ត្រមុនវិសោធនកម្មឆ្នាំ២០១៥ បានចែងថាការគណនាចំនួនអាសនៈថ្មីរបស់រដ្ឋសភាត្រូវធ្វើឡើងនៅឆ្នាំទីបីនៃនីតិកាលរបស់រដ្ឋសភា ដូច្នេះដើម្បីគណនាអាសនៈឆ្នាំ២០១៨ ត្រូវយកចំនួនប្រជាពលរដ្ឋនៅឆ្នាំ២០១៥។

ដូច្នេះ **$ច_{ផ}$** = ១៥.៤០៥.១៥៧ / ១២១.៦៤៧ = ១២៦[viii] (ដោយពុំគិតចំនួនសល់)

ខាងក្រោមនេះជារូបមន្តដើម្បីគណនារកចំនួនអាសនៈតាមខេត្ត/ក្រុង៖

**ប/ ផ = ច**

**ប** ជាចំនួនប្រជាពលរដ្ឋខ្មែរក្នុងខេត្ត ក្រុង

**ផ** ជាផលចែកប្រភាគដែលបានមកពីការគណនាខាងលើ

**ច** ជាចំនួនអាសនៈថ្មីក្នុងខេត្ត ក្រុងដោយពុំគិតចំនួនសល់

| ខេត្ត/ក្រុង | ចំនួនប្រជាជននៅឆ្នាំ២០១៥ [ix] | ចំនួនអាសនៈអនុម័តសម្រាប់នីតិកាលឆ្នាំ២០១៨ | ចំនួនអាសនៈគណនាដោយវេទិការអនាគតសម្រាប់នីតិកាលឆ្នាំ២០១៨ |
|---|---|---|---|
| បន្ទាយមានជ័យ | ៨០៦៧៨០ | ៦ | ៦ |
| បាត់ដំបង | ១២១៥៦០៥ | ៨ | ១០ |
| កំពង់ចាម+ត្បូងឃ្មុំ | ១៧៤១៣៥០ | ១៨ | ១៤ |
| កំពង់ឆ្នាំង | ៥៤២៧៣១ | ៤ | ៤ |
| កំពង់ស្ពឺ | ៧៩៧៨៣០ | ៦ | ៦ |
| កំពង់ធំ | ៦៨៤៧៩៥ | ៦ | ៥ |
| កំពត | ៦២៥៥២៦ | ៦ | ៥ |
| កណ្តាល | ១៤៤៣១០២ | ១១ | ១១ |
| កោះកុង | ១៤៩៥១៦ | ១ | ១ |
| ក្រចេះ | ៣៧៦៩៤១ | ៣ | ៣ |
| មណ្ឌលគិរី | ៨០៧៧១ | ១ | ១ |
| រាជធានីភ្នំពេញ | ១៨៣៥០៩០ | ១២ | ១៥ |
| ព្រះវិហារ | ១៩៦៧១៤ | ១ | ១ |
| ព្រៃវែង | ៩៨៣១៦៣ | ១១ | ៨ |
| ពោធិ៍សាត់ | ៤៤៧៥០៤ | ៤ | ៣ |
| រតនៈគិរី | ១៧៩៤៦៣ | ១ | ១ |
| សៀមរាប | ១០៩៦៤៨២ | ៦ | ៩ |
| ព្រះសីហនុ | ២៧២៩៣៣ | ៣ | ២ |
| ស្ទឹងត្រែង | ១៣២៩៧៦ | ១ | ១ |
| ស្វាយរៀង | ៥០៣៤៣២ | ៥ | ៤ |
| តាកែវ | ៨៨៦០៩៦ | ៨ | ៧ |
| កែប[x] | ៤៦០៩៨ | ១ | ១ |
| ប៉ៃលិន | ១០៧,៤៣៣ | ១ | ១ |
| ឧត្តរមានជ័យ | ២៥២៨២៦ | ១ | ២ |
| សរុប | ១៥៤០៥១៥៧ | ១២៥ | ១២១ |

---

[i] ចំនួនប្រជាជនជាចំនួនក្នុងឆ្នាំដែលអាសនៈរដ្ឋសភាត្រូវគណនា (ឧ.ឆ្នាំទីបីនៃនីតិកាលរដ្ឋសភាមុនពេលបោះឆ្នោត)។ ឧទាហរណ៍ ចំនួនអាសនៈសម្រាប់នីតិកាលឆ្នាំ២០០៣ ត្រូវគណនានៅក្នុងឆ្នាំ២០០០ ដូចគ្នាដែរអាសនៈឆ្នាំ២០០៨ ត្រូវគណនាក្នុងឆ្នាំ២០០៥ និងបន្តបន្ទាប់ វេទិកាអនាគតប្រើតួលេខចំនួនប្រជាជនដែលចេញផ្សាយដោយធនាគារពិភពលោក(អាចទាញយកតាមរយៈ៖

http://data.worldbank.org/country/cambodia) ដោយសារមិនមានទិន្នន័យអំពីចំនួនប្រជាពលរដ្ឋជាក់ស្តែងតាមឆ្នាំនីមួយៗក្នុងចន្លោះការធ្វើជំរឿនប្រជាជន និងការអង្កេតចន្លោះជំរឿនប្រជាសាស្ត្រ។ ដោយឡែកចំនួនប្រជាជននៅក្នុងឆ្នាំ១៩៩៣-១៩៩៤ និងឆ្នាំ១៩៩៨ ជាចំនួនប្រជាជនជាក់ស្តែងនៅក្នុងឆ្នាំនៃនីតិកាលទាំងនេះ ដែលដកស្រង់ចេញពីរបាយការណ៍អង្កេតចន្លោះជំរឿនប្រជាសាស្ត្រឆ្នាំ២០១៣ (អាចទាញយកបានតាមរយៈ៖ http://www.stat.go.jp/info/meetings/cambodia/pdf/ci_fn02.pdf)។ ចំនួនអាសនៈឆ្នាំ១៩៩៣ ត្រូវបានគណនាដោយប្រើចំនួនអ្នកចុះឈ្មោះបោះឆ្នោត មិនមែនចំនួនប្រជាពលរដ្ឋសរុបទេ។

[ii] វេទិកាអនាគតមិនអាចគណនាចំនួនអាសនៈបែងចែកតាមខេត្តសម្រាប់នីតិកាលរដ្ឋសភាមុនៗទេ ដោយសារមិនមានតួលេខចំនួនប្រជាជនគ្រប់គ្រាន់ក្នុងខេត្តនីមួយៗតាមឆ្នាំដែលត្រូវគណនា។

[iii] ជំរឿនប្រជាជនត្រូវបានធ្វើឡើងចំនួនពីរដងនៅកម្ពុជា៖ ឆ្នាំ១៩៩៨ និងឆ្នាំ២០០៨ ដូច្នេះតួលេខចំនួនប្រជាជនសម្រាប់ឆ្នាំ២០១៥ ជាតួលេខព្យាករណ៍ប្រជាសាស្ត្រ ដកស្រង់ចេញពីរបាយការណ៍ព្យាករណ៍ប្រជាសាស្ត្រសម្រាប់កម្ពុជា ២០០៨-២០៣០ របស់ការិយាល័យស្ថិតិជប៉ុន (Statistic Bureau Japan) ទាញយកពី៖ http://www.stat.go.jp/info/meetings/cambodia/pdf/rp12_ch10.pdf ។

[iv] ផលចែកប្រភាគ (ផ)សម្រាប់នីតិកាលរដ្ឋសភាឆ្នាំ២០១៣ មានចំនួន ១១២៧៤៩ មានន័យថាភ្នំពេញគួរទទួលបានអាសនៈមួយបន្ថែមទៀតដែលមានអាសនៈសរុប ១៣ និងខេត្តសៀមរាបគួរមានអាសនៈសរុប ៨តាំងពីនីតិកាលឆ្នាំ២០១៣ ដោយចំនួនប្រជាជនភ្នំពេញមាន ១,៥ លាន និងសៀបរាប ០,៩ លានក្នុងឆ្នាំ២០១០។ សំគាល់៖ ផលចែកប្រភាគ (ផ) ជាផល់ចែកនៃចំនួនប្រជាជនសរុបឆ្នាំ២០០៨ នឹង ១២៣ (ចំនួអាសនៈក្នុងរដ្ឋសភាសរុបក្នុងពេលគណនា)។

[v] ខេត្តឧត្តរមានជ័យត្រូវបានកាត់ចេញពីខេត្តសៀមរាបជាខេត្តថ្មីមួយក្នុងឆ្នាំ១៩៩៩។

[vi] ខេត្តកំពង់ចាមជាខេត្តដែលមានចំនួនប្រជាជនច្រើនជាងគេត្រូវបានបែងចែកជាខេត្តពីរគឺ ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣។ បើទោះបីជាការបែងចែកអាសនៈក្នុង ច.ប.ជ.ត វិសោធនកម្មឆ្នាំ២០១៥ ផ្តល់ការបែកចែកអាសនៈក្នុងខេត្តទាំងពីរ ក៏ដោយ សម្រាប់គោលបំណងនៃអត្ថបទវិភាគនេះ វេទិកាអនាគតចាត់ទុកខេត្តទាំងពីររួមជាខេត្តមួយ ដោយសារមិនមាន តួលេខចំនួនប្រជាជនក្នុងខេត្តនីមួយៗរហូតដល់មានជំរឿនប្រជាជនថ្មីដែលនឹងធ្វើឡើងនៅឆ្នាំ ២០១៨។

[vii] ខេត្តមួយចំនួននេះមានតួលេខប្រែប្រួលតិចតួចទាំងកំណើន និងការថយចុះប្រជាពលរដ្ឋតាំងពីឆ្នាំ១៩៩៨។ ទោះជាយ៉ាងណាក្នុងបរិបទកំណើនប្រជាជននៅទូទាំងប្រទេស អាសនៈសរុបក្នុងរដ្ឋសភាមិនមានការប្រែប្រួលក្នុងនីតិកាលមុនៗរបស់រដ្ឋសភា ដែលធ្វើឲ្យផលប្រភាគ (ផ)កាន់តែធំ ហើយក៏ជាកត្តាធ្វើឲ្យការបែងចែកចំនួនអាសនៈនៃមណ្ឌលទាំងនេះថយចុះ រឺនៅថេរ។

[viii] គួរបញ្ជាក់ថាតាមរយៈការគណនាខាងលើចំនួនអាសនៈសរុបគួរមានចំនួន ១២៦ ទោះជាយ៉ាងណាមានតែចំនួនអាសនៈសរុប ១២១ ត្រូវបានបែងចែកតាមខេត្ត។ ការថយចុះចំនួន ៥អាសនៈនេះ ដោយសាតែលទ្ធផលនៃការគណនាចំនួនអាសនៈតាមខេត្តមិនគិតចំនួនសល់។ មាត្រា៩ នៃច.ប.ជ.ត (២០១២) ចែងថា "ក្នុងការរកចំនួនអាសនៈតាមខេត្ត/ក្រុងត្រូវគណនាតាមរូបមន្តខាងក្រោម៖
ប (ជាចំនួនប្រជាពលរដ្ឋខ្មែរក្នុងខេត្ត/ក្រុង)/ ផ(ជាផលចែកប្រភាគដែលបានមកពីការគណនាខាងលើ) = ច (ជាចំនួនអាសនៈថ្មីក្នុងខេត្តក្រុង ដោយពុំគិតចំនួនសល់)។"

[ix] របាយការណ៍ព្យាករណ៍ប្រជាសាស្ត្រសម្រាប់កម្ពុជា ២០០៨-២០៣០ របស់ការិយាល័យស្ថិតិជប៉ុន (Statistic Bureau Japan)
http://www.stat.go.jp/info/meetings/cambodia/pdf/rp12_ch10.pdf

[x] ខេត្តកែបទទួលបានមួយអាសនៈបើទោះបីជាចំនួនប្រជាជននៅក្នុងខេត្តនេះ មានតែ ៤៦០៩៨ តិចជាងផលចែកប្រភាគ **(ផ)** រឺប្រហែល **0,៤** អាសនៈ។ មាត្រ១០ ច.ប.ជ.ត (២០១២) បានចែងថា "ចំពោះខេត្ត ក្រុងណាដែលមានប្រជាពលរដ្ឋតិចជាងផលចែកប្រភាគក៏ត្រូវមានអាសនៈមួយដែរ។" បើទោះបីជាមាត្រា១០ត្រូវបានដកចេញពី ច.ប.ជ.ត វិសោធនកម្មឆ្នាំ២០១៥ ក៏ដោយខេត្តកែបនៅតែទទួលបានមួយអាសនៈនៅក្នុងច្បាប់នេះ។